# សេចក្តីប្រកាសព័ត៌មានរបស់អ.វ.ត.ក

អង្គបុរេជំនុំជម្រះកំណត់យកថ្ងៃអង្គារ ទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ១០:៣០ នាទីព្រឹក ជាថ្ងៃបើកសវនាការជាសាធារណៈក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទឈ្មោះ កាំង ហ្កេចអ៊ាវ ហៅ ឌុច។ (សូមមើលសេចក្តីសម្រេចអំពីការកំណត់ថ្ងៃបើកសវនាការ)

សវនាការនឹងប្រព្រឹត្តឡើងតាមសេចក្តីណែនាំមួយដែលនឹងធ្វើឡើងជាសាធារណៈផងដែរនាម៉ោង១០ព្រឹកក្នុង ថ្ងៃព្រហស្បត៍ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ។ ព្រឹត្តិការណ៍នាថ្ងៃទី ១៥ នោះដែរនឹងមានការពិភាក្សាទៅលើនីតិវិធីផ្សេងៗសំរាប់ត្រៀមរៀបចំសវនាការដ៏មានសារៈសំខាន់នាថ្ងៃទី ២០ ខែវិច្ឆិកា។

សំរាប់ព័ត៌មានពិស្តារទាក់ទងនឹងសាធារណជននិងអ្នកសារព័ត៌មានក្នុងការយកព័ត៌មានអំពីសវនាការនឹងមានផ្សាយជូនក្នុងពេលឆាប់ៗនេះ។